ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ.......................................................

# មតិស្វាគមន៍
## ឯកឧត្តម ជា ចាន់តូ ទេសាភិបាល ធនាគារជាតិនៃកម្ពុជា ថ្លែងក្នុងពិធី ចុះហត្ថលេខាលើអនុស្សារណៈយល់គ្នា រវាងធនាគារជាតិនៃកម្ពុជា និង គណៈកម្មការសេវាហិរញ្ញវត្ថុកូរ៉េ

នៅធនាគារជាតិនៃកម្ពុជា ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៣

សូមគោរព ៖

- ឯកឧត្តម Kyung Ho CHOO អនុប្រធានគណៈកម្មការសេវាហិរញ្ញវត្ថុកូរ៉េ
- ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា និងសមាជិកគណៈប្រតិភូទាំងអស់ ជាទីស្នេហា

ថ្ងៃនេះ តាងនាមឲ្យថ្នាក់ដឹកនាំនិងមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជា ខ្ញុំមានកិត្តិយស និងក្តីសោមនស្សរីករាយជាទីបំផុត ដោយធនាគារជាតិនៃកម្ពុជាបានរៀបចំកិច្ចប្រជុំទ្វេភាគី ជាមួយគណៈកម្មការសេវាហិរញ្ញវត្ថុកូរ៉េ ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការលើការផ្តល់ជំនួយ បច្ចេកទេស និងការត្រួតពិនិត្យវិស័យធនាគារនិងហិរញ្ញវត្ថុរវាងស្ថាប័នទាំងពីរ ។

គណៈប្រតិភូនៃធនាគារជាតិនៃកម្ពុជា និងគណៈកម្មការសេវាហិរញ្ញវត្ថុបានប្រជុំពិភាក្សា អំពីស្ថានភាពបច្ចុប្បន្ននៃសេដ្ឋកិច្ចនិងវិស័យហិរញ្ញវត្ថុសកល និងកូរ៉េ ការអភិវឌ្ឍសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅកម្ពុជា និងវិធានការនានាដើម្បីពង្រឹងចំណងកិច្ចសហប្រតិបត្តិការ និងភាព ជាដៃគូនៃស្ថាប័នទាំងពីរ ឲ្យកាន់តែជិតស្និទ្ធនិងប្រសើរឡើងបន្ថែមទៀតនាពេលខាងមុខ ។ កិច្ចប្រជុំនេះមានសារៈសំខាន់ណាស់ ព្រោះជាវេទិកាសម្រាប់ផ្លាស់ប្តូរព័ត៌មានថ្មីៗក្នុងវិស័យ ធនាគារនិងហិរញ្ញវត្ថុ និងពង្រឹងកិច្ចសហប្រតិបត្តិការប្រកបដោយស្មារតីសាមគ្គីភាពនិង ភាតរភាព។

ដោយយល់ឃើញពីផលប្រយោជន៍រួម និងសេចក្តីត្រូវការចាំបាច់របស់ស្ថាប័ននិងប្រជាជន នៃប្រទេសទាំងពីរ នាពេលបច្ចុប្បន្ននិងពេលអនាគតក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចប្រកប ដោយចីរភាព ទើបធនាគារជាតិនៃកម្ពុជានិងគណៈកម្មការសេវាហិរញ្ញវត្ថុកូរ៉េ ប្រារព្ធពិធីចុះ ហត្ថលេខាលើអនុស្សរណៈយល់គ្នា ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការលើការផ្តល់ជំនួយ បច្ចេកទេស និងការត្រួតពិនិត្យវិស័យធនាគារនិងហិរញ្ញវត្ថុរវាងស្ថាប័នទាំងពីរ នៅថ្ងៃនេះ ។

**សូមអរគុណ!**

ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧